ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ

លេខ : ✓ មស.

# សាររំលែកមរណទុក្ខ
## ជូនចំពោះ
## ឯកឧត្តម ជុក មុន្នី រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ និងក្រុមគ្រួសារ

ខ្ញុំ និងក្រុមគ្រួសារ ព្រមទាំងថ្នាក់ដឹកនាំ មន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈទាំងអស់ មានក្តីក្តុកក្តួលរន្ធត់ចិត្តយ៉ាងខ្លាំង ដោយបានទទួលដំណឹងថា ឧបាសិកា **ប៊ួយ សុទ្ធ** ដែលត្រូវជាម្តាយឯកឧត្តម បានទទួលមរណភាពកាលពីថ្ងៃសៅរ៍ ៣រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤ ត្រូវនឹងថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២០ វេលាម៉ោង ១០:០០នាទីយប់ ដោយជរាពាធ។

ក្នុងឱកាសប្រកបដោយក្តីរំជួលចិត្តនិងសមានចិត្តដ៏ក្រៀមក្រំនេះ ខ្ញុំនិងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការក្រសួងមុខងារសាធារណៈទាំងអស់ សូមសម្តែងនូវមរណទុក្ខដ៏ជ្រាលជ្រៅ ពោរពេញដោយក្តីសោកស្តាយជាអនេកប្បការជូនចំពោះឧបាសិកា **ប៊ួយ សុទ្ធ** ដែលបានធ្វើមរណកាលលាចាកលោក លាចាកពីបុត្រធីតានិងក្រុមញាតិគ្រួសារជាទីស្រលាញ់។

ខ្ញុំសូមឧទ្ទិសបួងសួងជូនវិញ្ញាណក្ខន្ធរបស់ឧបាសិកា **ប៊ួយ សុទ្ធ** បានទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តម** និងក្រុមគ្រួសារ មេត្តាទទួលនូវការរំលែកទុក្ខដ៏ក្រៀមក្រំបំផុតពីខ្ញុំ។ល

ថ្ងៃអាទិត្យ ៤រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២០

**រដ្ឋមន្ត្រី**

**ហ៊ុំ សុខា**

ផ្លូវវត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**
លេខ : ✓ មស.

# សេចក្តីជូនដំណឹង

ក្រសួងមុខងារសាធារណៈ សូមជម្រាបជូន **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ជាថ្នាក់ដឹកនាំនិងមន្ត្រីរាជការក្រសួងទាំងអស់មេត្តាជ្រាបថា ឯកឧត្តម **ហ៊ុំ សុខា** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ បានចាត់គណៈប្រតិភូក្រសួងដឹកនាំដោយឯកឧត្តម **អែម ម៉ុនថុល** រដ្ឋលេខាធិការ ដើម្បីអញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធឧបាសិកា **ប៊ួយ សុខ** មាតាឯកឧត្តម **ដុក មុន្នី** រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ។ ពិធីគោរពវិញ្ញាណក្ខន្ធនេះ នឹងប្រព្រឹត្តទៅនាព្រឹកថ្ងៃចន្ទ ៥រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤ ត្រូវនឹងថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២០ នៅភូមិត្រពាំងផ្អែល ឃុំម្រោម ស្រុកអង្គរជ័យ ខេត្តកំពត។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើនេះ សូមឯកឧត្តម លោកជំទាវ លោក លោកស្រី មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃអាទិត្យ ៤រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២០